ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃអង្គារ ១០កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន៥៩ ដែលមានទុនវិនិយោគសរុបប្រមាណ៨៦០លានដុល្លារអាម៉េរិក ត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងខែមេសា ឆ្នាំ២០២៥

ក្នុងខែមេសា ឆ្នាំ២០២៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងវិនិយោគសរុបចំនួន**៥៩គម្រោង** ដែលមានទុនវិនិយោគសរុបប្រមាណ**៨៦០លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានប្រមាណ**៣៩ពាន់**កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគសរុប គម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន៣២គម្រោង និងគម្រោងវិនិយោគដែលមានទីតាំងស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសមានចំនួន២៧គម្រោង។ ជារួម ការអនុម័តគម្រោងវិនិយោគមានការកើនឡើងចំនួន៣៧គម្រោង ស្មើនឹងប្រមាណ ១៦៨% ខណៈទុនវិនិយោគមានការកើនឡើងប្រមាណជាង៥៥០លានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ១៧៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ដោយឡែក នៅក្នុងរយៈពេល៤ខែនៃឆ្នាំ២០២៥នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុម័តគម្រោងវិនិយោគចំនួន ២៣១គម្រោង ក្នុងទុនវិនិយោគមានប្រមាណ ៣,៤៣ពាន់លានដុល្លារអាម៉េរិក។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ចំនួនគម្រោងបានកើនឡើងចំនួន ១០៣គម្រោង ស្មើនឹងប្រមាណ៨០% ខណៈទុនវិនិយោគបានកើនឡើងប្រមាណជាង ៨៥៦ លានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ ៣៤%។

ជាការកត់សម្គាល់ គម្រោងវិនិយោគដែលមានភាពលេចធ្លោជាងគេប្រចាំខែមេសា រួមមានៈ

ក. ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| វិស័យហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | គម្រោងវិនិយោគបង្កើតផែស្ងួត |
| | -ទីតាំងៈ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ |
| | -ទុនវិនិយោគៈ ១១លានដុល្លារអាម៉េរិក |
| | -បង្កើតការងារៈ ១៣៦កន្លែង។ |
| វិស័យឧស្សាហកម្ម | គម្រោងវិនិយោគបង្កើតរោងចក្រផលិត និងផ្គុំដំឡើងបន្ទះសូឡា និងគ្រឿងបង្គុំ |
| | -ទីតាំងៈ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ |
| | -ទុនវិនិយោគៈ ៤៤លានដុល្លារអាម៉េរិក |
| | -បង្កើតការងារៈ ២៥០កន្លែង។ |

| | |
|---|---|
| វិស័យឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតឧបករណ៍បរិក្ខារពេទ្យ** |
| | -ទីតាំង៖ ស្រុកបាទី ខេត្តតាកែវ |
| | -ទុនវិនិយោគ៖ ១៧លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ៣៩៨កន្លែង។ |
| វិស័យទេសចរណ៍ | **គម្រោងវិនិយោគបង្កើតរមណីយដ្ឋានទេសចរណ៍សេវាកម្មចម្រុះ** |
| | -ទីតាំង៖ ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង |
| | -ទុនវិនិយោគ៖ ២០លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ១៤២កន្លែង។ |

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| វិស័យឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសំបកកង់រថយន្ត** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស អាយ អេស អាយ (ខេត្តព្រះសីហនុ) |
| | -ទុនវិនិយោគ៖ ២៤២លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ២.៤០៨កន្លែង។ |
| | **គម្រោងពង្រីកផលិតកម្មផលិតសំបកកង់រថយន្ត** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ឈី លូ ជាន ពុ ចាយ (ខេត្តស្វាយរៀង) |
| | -ទុនវិនិយោគបន្ថែម៖ ៩៣លានដុល្លារអាម៉េរិក។ |
| | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះ** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស ឈីលូ ជាន ពុ ចាយ (ខេត្តស្វាយរៀង) |
| | -ទុនវិនិយោគ៖ ៤០លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ៧៦៧កន្លែង។ |
| | **គម្រោងវិនិយោគបង្កើតរោងចក្រផលិតសម្ភារៈប្រើប្រាស់ក្នុងផ្ទះធ្វើពីលោហធាតុ និងប្លាស្ទិក** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស កោះកុង បេជាង (ខេត្តកោះកុង) |
| | -ទុនវិនិយោគ៖ ១៩លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ៤៩៩កន្លែង។ |
| | **គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំ និងដំឡើងត្រីចក្រយានយន្តអគ្គិសនី** |
| | -ទីតាំង៖ តំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ (រាជធានីភ្នំពេញ) |
| | -ទុនវិនិយោគ៖ ១៥លានដុល្លារអាម៉េរិក |
| | -បង្កើតការងារ៖ ៤៧៥កន្លែង។ |

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ខែមេសា ឆ្នាំ២០២៥

ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការវិនិយោគកម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**គម្រោងវិនិយោគ**
**៥៩** (២៧ គម្រោង
ក្នុងតំបន់សេដ្ឋកិច្ចពិសេស)

**ទុនវិនិយោគ**
**៨៦០** លាន
ដុល្លារអាម៉េរិក

**បង្កើតការងារ**
**~៣៩ពាន់**
កន្លែង

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)

**៧៣ លាន**
វិស័យហេដ្ឋារចនាសម្ព័ន្ធ
និងផ្សេងៗ

**២០ លាន**
វិស័យទេសចរណ៍



**៧៦៧ លាន**
វិស័យឧស្សាហកម្ម

## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. ចិន | ៥៨,៥១% |
| ២. សិង្ហបុរី | ៣៥,១០% |
| ៣. កម្ពុជា | ៤,៥១% |
| ៤. អង់គ្លេស | ១,៦៥% |
| ៥. សហរដ្ឋអាមេរិក | ០,២៣% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត




**កំណត់សម្គាល់**
- # ចំនួនគម្រោង
- ១១+
- ៦-១០
- ១-៥
- មិនមាន